**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ១៣៥/២៥ ក.ប/ស.ណ.ន.ស.ជ.ក

# សេចក្តីណែនាំ
# ស្តីពី
# ការព្យួរកិច្ចសន្យាការងារ

យោងតាមមាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ សហគ្រាស ក្រុមហ៊ុន រោងចក្រដែលជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសម្ភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ អាចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (Labour Centralized Management System-LACMS) តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh ដោយអនុវត្តដូចខាងក្រោម៖

១- ត្រូវជូនដំណឹងឱ្យបានទូលំទូលាយដល់កម្មករនិយោជិតដោយបញ្ជាក់អំពីកាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់ការព្យួរកិច្ចសន្យាការងារ ឈ្មោះ និងចំនួនកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារទាំងស្រុង តាមផ្នែក ឬតាមក្រុម នៅតាមខ្សែច្រវាក់ផលិតកម្ម។

២- ត្រូវមានកិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារដោយមានការឯកភាពយ៉ាងតិច ពីរភាគបី នៃចំនួនប្រតិភូបុគ្គលិកពេញសិទ្ធិប្រចាំសហគ្រាស ក្រុមហ៊ុន រោងចក្រ។ ក្នុងករណីមិនទាន់មានប្រតិភូបុគ្គលិក ត្រូវមានការឯកភាពពីកម្មករនិយោជិតយ៉ាងតិច ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនកម្មករនិយោជិតសរុប ដែលត្រូវព្យួរកិច្ចសន្យាការងារ និងត្រូវបិទផ្សាយកិច្ចព្រមព្រៀងនោះ នៅលើក្តារផ្សាយព័ត៌មានរបស់សហគ្រាស ក្រុមហ៊ុន រោងចក្រ។

៣- ត្រូវបំពេញបែបបទអំពីការព្យួរកិច្ចសន្យាការងារក្នុងប្រព័ន្ធ LACMS ឱ្យបានយ៉ាងតិច ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទនៃការចាប់ផ្តើមព្យួរកិច្ចសន្យាការងារស្របតាមការណែនាំអំពីរបៀបព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារដូចមានក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។

៤- ជ្រើសរើសកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារ និងរៀបចំបញ្ជីរាយនាមកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវតាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំនេះ ដោយតម្រូវឱ្យសាមីកម្មករនិយោជិតផ្តិតម្រាមដៃបញ្ជាក់អំពីភាពត្រឹមត្រូវលើព័ត៌មានរបស់ខ្លួនមានជាអាទិ៍ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លេខលិខិតឆ្លងដែនសម្រាប់ជនបរទេស លេខទូរសព្ទ។

៥- ត្រូវទាញលិខិតព្យួរកិច្ចសន្យាការងារ ដើម្បីចុះហត្ថលេខា និងបោះត្រាសហគ្រាស ក្រុមហ៊ុន រោងចក្រឱ្យបានត្រឹមត្រូវតាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំនេះ រួចបញ្ចូលក្នុងប្រព័ន្ធវិញ។

៦- ត្រូវបញ្ចូលបញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលព្យួរកិច្ចសន្យាការងារជាទម្រង់ EXCEL FILE។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៧- ក្នុងករណីបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់ (ចូលធ្វើការងារវិញ) ត្រូវរាយការណ៍ចូលក្នុងប្រព័ន្ធ LACMS ឱ្យបានមុនយ៉ាងតិច ២ (ពីរ) ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃចូលធ្វើការវិញ តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃសេចក្តីណែនាំនេះ។

៨- ត្រូវរក្សាទុកឯកសារពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារសម្រាប់អធិការការងារធ្វើការត្រួតពិនិត្យ។

ការព្យួរកិច្ចសន្យាការងារ ដែលទទួលបានការអនុញ្ញាតនៅមុនកាលបរិច្ឆេទអនុវត្តសេចក្តីណែនាំនេះត្រូវបន្តមានសុពលភាពរហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃការអនុញ្ញាតនោះ។

ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រដែលអនុវត្តមិនបានត្រឹមត្រូវតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ត្រូវទទួលការផ្តន្ទាទោសស្របតាមច្បាប់ជាធរមាន។

ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិត ត្រូវអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១៖ ការណែនាំអំពីរបៀបព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ*

- ចូលទៅកាន់គេហទំព័រ http://lacms.mlvt.gov.kh/
- ចូលប្រព័ន្ធដោយប្រើប្រាស់អ៊ីមែល និងលេខសម្ងាត់ ដែលបានបង្កើតក្នុងប្រព័ន្ធ LACMS។ ក្នុងករណីមិនទាន់មានគណនី ត្រូវចុះឈ្មោះបង្កើតគណនីសហគ្រាសក្នុងប្រព័ន្ធ LACMS ជាមុនសិន។
- ចុចលើពាក្យ «ការព្យួរកិច្ចសន្យាការងារ»

**១** ធ្វើបច្ចុប្បន្នភាពព័ត៌មានមួយចំនួនមានជាអាទិ៍ សកម្មភាពអាជីវកម្មចម្បង, ផលិតផលចម្បង, ផលិតផលម៉ាក, ការនាំចេញ, លេខគណនីធនាគារ, ឈ្មោះធនាគារ និងភ្ជាប់បណ្ណពន្ធប៉ាតង់ឆ្នាំចុងក្រោយ

**២** បំពេញកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់, មូលហេតុនៃការព្យួរកិច្ចសន្យាការងារ, ប្រាក់ឧបត្ថម្ភអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ (ប្រចាំខែ ឬអំឡុងពេលព្យួរ), ឈ្មោះ ភេទ តួនាទី និងលេខទូរសព្ទអ្នករៀបចំព្យួរ

**៣** បញ្ចូលបញ្ជីកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារជា EXCEL FILE

**៤**
- ទាញយកលិខិតព្យួរកិច្ចសន្យាការងារ ដើម្បីចុះហត្ថលេខា និងបោះត្រា រួចស្កេនភ្ជាប់មកប្រព័ន្ធវិញជាទម្រង់ PDF FILE
- ទាញយកបញ្ជីរាយនាមកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារដើម្បីឱ្យសាមីកម្មករនិយោជិតផ្តិតម្រាមដៃ រួចបោះត្រាគ្រប់ទំព័រ និងស្កេនភ្ជាប់មកប្រព័ន្ធវិញជាទម្រង់ PDF FILE
- បញ្ចូលកិច្ចព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាការងារ ជាទម្រង់ PDF FILE
- បញ្ចូលបញ្ជីបើកប្រាក់ឈ្នួលខែចុងក្រោយ ជាទម្រង់ EXCEL FILE

**៥**
- ចុចសញ្ញាធីក ☑ បញ្ជាក់ភាពត្រឹមត្រូវនៃព័ត៌មានដែលបានបំពេញ និងការទទួលខុសត្រូវ
- ចុចរក្សាទុក និងបញ្ជូនករណីមិនមានអ្វីត្រូវកែប្រែទៀត។ ក្រោយបញ្ជូនរួចរាល់ លោកអ្នកនឹងទទួលបានលិខិតព្យួរកិច្ចសន្យាការងារក្នុងប្រព័ន្ធ LACMS។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកប្រព័ន្ធទាន់ហេតុការណ៍លេខ «១២៨៦»

# ឧបសម្ព័ន្ធទី២៖ បញ្ជីរាយនាមកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារ

**បញ្ជីរាយនាមកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារ**

នាមករណ៍សហគ្រាស ក្រុមហ៊ុន រោងចក្រ..............................................................................................................................................

ជាអក្សរឡាតាំង..............................................................................................................................................................

សកម្មភាពអាជីវកម្មចម្បង.................................................................................. ផលិតផលចម្បង..............................................................................

អាសយដ្ឋាន ផ្ទះលេខ....... ផ្លូវ............ ភូមិ......................... ឃុំ/សង្កាត់...................ក្រុង/ស្រុក/ខណ្ឌ..................... រាជធានី/ខេត្ត...........................................

ចំនួនកម្មករនិយោជិតព្យួរ...........ស្រី........ (បរទេសសរុប........ស្រី........)នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប...........ស្រី........ (បរទេសសរុប.......ស្រី........)នាក់

រយៈពេលព្យួរកិច្ចសន្យាការងារ................ថ្ងៃ ចាប់ពីថ្ងៃទី.............. ខែ.....................ឆ្នាំ២០២........ ដល់ថ្ងៃទី............. ខែ.....................ឆ្នាំ២០២........................

| ល.រ | ឈ្មោះកម្មករនិយោជិត | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លេខលិខិតឆ្លងដែន | លេខបណ្ណសមាជិក ប.ស.ស. | លេខអត្តសញ្ញាណការងាររបស់កម្មករនិយោជិតខ្មែរ | លេខសៀវភៅការងារជនបរទេស | ថ្ងៃ ខែ ឆ្នាំចូលធ្វើការ | បម្រើការនៅផ្នែក | លេខទូរសព្ទ | ស្នាមម្រាមដៃបញ្ជាក់របស់កម្មករនិយោជិត |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី....

ថ្ងៃទី........... ខែ.......... ឆ្នាំ២០២.....

**ឈ្មោះ ហត្ថលេខា និងត្រា**

**ម្ចាស់ ឬនាយក**

**សម្គាល់៖ សហគ្រាស ក្រុមហ៊ុន រោងចក្រត្រូវបោះត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ រួចត្រូវផ្ញើបញ្ជីនេះ ជា EXCEL FILE និងស្កេនបញ្ជីឈ្មោះដែលបោះត្រានៅគ្រប់ទំព័រជា PDF FILE មកក្នុងប្រព័ន្ធ LACMS។**

ឧបសម្ព័ន្ធទី៣៖ លិខិតជូនដំណឹងស្ដីពីការព្យួរកិច្ចសន្យាការងារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

នាមករណ៍សហគ្រាស ក្រុមហ៊ុន រោងចក្រ៖ ..........................................................................
ជាអក្សរឡាតាំង៖ ..........................................................................
លេខបញ្ជីពាណិជ្ជកម្ម៖ ..........................................................................
សកម្មភាពអាជីវកម្មចម្បង៖ ..........................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុងប.ស.ស.៖ ..........................................................................
លេខគណនីធនាគារ៖ ..........................................................................
អាសយដ្ឋាន៖ ..........................................................................
ទូរសព្ទលេខ៖.............................................អ៊ីមែល (E-mail)៖ ................................................

កម្មវត្ថុ ៖ ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន..........នាក់ រយៈពេល.............ថ្ងៃ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយមូលហេតុសហគ្រាស ក្រុមហ៊ុន រោងចក្ររបស់យើងខ្ញុំ .................................................................................................................... ដូច្នេះ សហគ្រាស ក្រុមហ៊ុន រោងចក្ររបស់យើងខ្ញុំសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន................នាក់ (ស្រី.....នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន................នាក់ (ស្រី..........នាក់) រយៈពេល........ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី.........ខែ........ឆ្នាំ២០២... រហូតដល់ថ្ងៃទី.......ខែ.............ឆ្នាំ២០២...។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្របានព្រមព្រៀងផ្ដល់ប្រាក់ឧបត្ថម្ភចំនួន ..............ដុល្លារអាម៉េរិក/នាក់។

ខ្ញុំសូមធានាអះអាងថាព័ត៌មាន និងឯកសារដែលបានបញ្ចូលក្នុងប្រព័ន្ធ គឺត្រូវបានធ្វើឡើងដោយសុចរិតភាព និងត្រឹមត្រូវ។ ប្រសិនបើមានព័ត៌មាន និងឯកសារណាមួយ ដែលខ្ញុំបានបំពេញដោយមានការក្លែងបន្លំ ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

.......... ថ្ងៃទី ..........ខែ ............. ឆ្នាំ២០២.....

ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

**សូមភ្ជាប់មកជាមួយ៖**

- កិច្ចព្រមព្រៀងស្ដីពីការព្យួរកិច្ចសន្យាការងារ
- បញ្ជីរាយនាមកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារ
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលព្យួរកិច្ចសន្យាការងារ

ឧបសម្ព័ន្ធទី៤៖ លិខិតបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

នាមករណ៍សហគ្រាស ក្រុមហ៊ុន រោងចក្រ៖ ......................................................................................
ជាអក្សរឡាតាំង៖ ......................................................................................................................
លេខបញ្ជីពាណិជ្ជកម្ម៖ .............................................................................................................
សកម្មភាពអាជីវកម្មចម្បង៖ .......................................................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុងប.ស.ស.៖ ..................................................................................
លេខគណនីធនាគារ៖ ..................................................................................................................
អាសយដ្ឋាន៖ ............................................................................................................................
ទូរសព្ទលេខ៖.............................................អ៊ីមែល (E-mail)៖ ...................................................

កម្មវត្ថុ ៖ ការបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់។
យោង ៖ លិខិតលេខ............. ចុះថ្ងៃទី............ ខែ........... ឆ្នាំ២០២...... ស្ដីពីការព្យួរកិច្ចសន្យាការងារចូលក្នុងប្រព័ន្ធ LACMS។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដោយមូលហេតុសហគ្រាស ក្រុមហ៊ុន រោងចក្ររបស់យើងខ្ញុំ.....................................................................................................................................
ដូច្នេះ សហគ្រាស ក្រុមហ៊ុន រោងចក្ររបស់យើងខ្ញុំនឹងបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់ដល់កម្មករនិយោជិតចំនួន..........នាក់ (ស្រី.....នាក់) ក្នុងចំណោមកម្មករនិយោជិតដែលបានព្យួរសរុបចំនួន...........នាក់ (ស្រី.......នាក់) ចាប់ពីថ្ងៃទី............ខែ...........ឆ្នាំ២០២...តទៅ។

ខ្ញុំសូមធានាអះអាងថាព័ត៌មាន និងឯកសារដែលបានបញ្ចូលក្នុងប្រព័ន្ធ គឺត្រូវបានធ្វើឡើងដោយសុចរិតភាព និងត្រឹមត្រូវ។ ប្រសិនបើមានព័ត៌មាន និងឯកសារណាមួយ ដែលខ្ញុំបានបំពេញដោយមានការក្លែងបន្លំ ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២.....
**ហត្ថលេខា និងត្រា**
**ម្ចាស់ ឬនាយក**

**សូមភ្ជាប់មកជាមួយ៖**
- បញ្ជីរាយនាមកម្មករនិយោជិតដែលបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់